សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## កិច្ចការស្រាវជ្រាវ

# ការប្រៀបធៀបប្រព័ន្ធបោះឆ្នោតប្រទេសកម្ពុជា និងប្រទេសថៃ


ស្រាវជ្រាវដោយ

និស្សិត: **ក្រុមទី ៤**

សាស្ត្រាចារ្យណែនាំ

ឯកឧត្តម **ម៉ុក ដារ៉ា**


ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤


**រក្សាសិទ្ធិដោយ** Khmer Famous

# ជំពូកទី ១. ប្រព័ន្ធច្បាប់បោះឆ្នោតប្រទេសកម្ពុជា[1]

## i. សញ្ញាណស្ដីពីការបោះឆ្នោត

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវអនុវត្តតាមគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្ដងកាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ លើកលែងតែនៅក្នុងស្ថានភាពណាមួយដូចខាងក្រោម

- ក្នុងករណីប្រធានស័ក្តិដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។
- ក្នុងករណីរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មី ត្រូវប្រព្រឹត្តទៅក្នុងរយៈហុកសិប (៦០) ថ្ងៃ យ៉ាងយូរចាប់ពីថ្ងៃរំលាយរដ្ឋសភា ។
- ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឱ្យបន្តនីតិកាលរបស់ខ្លួនស្របតាមកថាខណ្ឌ ទី ៥ មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានចែងក្នុងជំពូកទី៣ នៃច្បាប់នេះ ។

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅជាសកលដោយសេរីត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាពដោយចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមខេត្តក្រុងដោយយកខេត្តក្រុងជាមណ្ឌលបោះឆ្នោត ។អាសនៈនៅក្នុងរដ្ឋសភាមានចំនួនយ៉ាងតិចមួយរយម្ភៃ(១២០) រៀងរាល់ឆ្នាំទី៣ នៃនីតិកាលរបស់រដ្ឋសភា គណៈរដ្ឋមន្ត្រីត្រូវបង្កើត គណៈកម្មការកំណត់អាសនៈរដ្ឋសភា ដើម្បីធ្វើការកែប្រែចំនួនអាសនៈនិងបែងចែកអាសនៈតាមខេត្តក្រុង ។គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម

-តំណាងមួយរូបនៃគណបក្សនយោបាយនីមួយៗដែលមាន អាសនៈក្នុង រដ្ឋសភា ។

-តំណាងក្រសួងមហាផ្ទៃពីររូប ។

-នាយកនៃវិទ្យាស្ថានជាតិស្ថិតិ ។

គណៈកម្មការនេះដឹកនាំដោយប្រធានមួយរូបអមដោយអនុប្រធានមួយរូបដែលជ្រើសតាំងក្នុងចំណោមសមាជិកគណៈកម្មការដោយការបោះឆ្នោតតាមមតិភាគច្រើនដាច់ខាតពីសមាជិកគណៈកម្មការនេះ ។គណៈកម្មការនេះត្រូវធ្វើរបាយការណ៍ និងលើកសំណើអំពីការ បន្ថែមអាសនៈ ឬការរក្សាទុកចំនួនអាសនៈនៅដដែលជូនរដ្ឋាភិបាលដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋស្ថានភាពភូមិសាស្ត្រសង្គមសេដ្ឋកិច្ច ។រាជរដ្ឋាភិបាលត្រូវធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការកំណត់ចំនួនអាសនៈនេះជូនរដ្ឋសភាអនុម័ត ។ក្នុងករណីខកខានពុំបានកំណត់ជាថ្មីនូវចំនួនអាសនៈក្នុងរដ្ឋសភចំនួនអាសនៈនោះត្រូវយកតាមចំនួនអាសនៈរដ្ឋសភាដែលមានក្នុងនីតិកាលចុងក្រោយ ។ចំនួនអាសនៈដែលត្រូវមាន

[1]ព្រះរាជក្រម/លេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២

នៅក្នុងរដ្ឋសភានិងចំនួនអាសនៈដែលត្រូវបែងចែកតាមខេត្តក្រុងត្រូវផ្សព្វផ្សាយជាសាធារណៈយ៉ាងតិចមួយឆ្នាំមុនថ្ងៃបោះឆ្នោត ។ចំពោះខេត្តក្រុងណាដែលមានប្រជាពលរដ្ឋតិចជាងផលចែកប្រភាគ ក៏ត្រូវមានអាសនៈមួយដែរ ។

ចំពោះអាសនៈដែលនៅសល់ គណៈកម្មការកំណត់អាសនៈរដ្ឋសភា អាចធ្វើសំណើបន្ថែមអាសនៈទៅខេត្តក្រុងដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រសង្គមនិងសេដ្ឋកិច្ច ។

## ផ្នែកទី១. ការគ្រប់គ្រងការបោះឆ្នោត

## ១.គណៈកម្មការជាតិរៀបចំការបោះឆ្នោត

### ក. សមាសភាព

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវគ្រប់គ្រងដោយគណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោតហៅកាត់ គ.ជ.ប ។ គណៈកម្មាធិការខេត្តក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោតដើម្បីអនុវត្តការងាររបស់ខ្លួន។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការ ឯករាជនិងអព្យាក្រឹតក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។

សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវមានជំហរអព្យាក្រឹតឥតលំអៀងក្នុងការអនុវត្តការងារបោះឆ្នោត ។គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាពដូចតទៅ :

-ឥស្សរជនខ្មែរមួយរូបប្រធាន

-ឥស្សរជនខ្មែរមួយរូបអនុប្រធាន

-ឥស្សរជនខ្មែរប្រាំពីររូបសមាជិក

ប្រធានអនុប្រធាននិងសមាជិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសមត្ថភាពខាងនយោបាយ បទពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។ប្រធានអនុប្រធាននិងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិចប្រាំពីរ(៧) ខែមុនថ្ងៃបោះឆ្នោតតាមសំណើររបស់គណៈរដ្ឋមន្ត្រីក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។ប្រធានអនុប្រធាននិងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានកាតព្វកិច្ចដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងតិចប្រាំបួន (៩)ខែ មុនថ្ងៃបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិជ្រើសរើសបុគ្គលិក តាមការចាំបាច់សម្រាប់ដំ ណើរការបោះឆ្នោត និងមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។ ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្មី ឱ្យបានសម្រេចយ៉ាងយូរហុកសិប (៦០)ថ្ងៃ បន្ទាប់ពីថ្ងៃរំលាយរដ្ឋសភា ។ប្រធានអនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិ

រៀបចំការ បោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយ ឬ/និងជាអ្នកស្ថិតក្នុងជួរអ្នកដឹកនាំនៃ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលសមាគមសហជីពឬ/និងជាមន្ត្រីរាជការក្រោយពី បានទទួលការតែងតាំងក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសុំលាលែងជាស្ថាពរពីគណបក្សនយោបាយឬ/និងពីជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលសមាគមសហជីព ឬ/និថដាក់ពាក្យសុំទៅបំរើការងារក្រៅ ក្របខ័ណ្ឌរហូតដល់ថ្ងៃចប់អណត្តិ។ ប្រធានអនុប្រធាននិងសមាជិកនៃគណៈកម្មការខេត្តក្រុងឃុំសង្កាត់រៀបចំការបោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយ ឬ និងជាមន្ត្រីរាជការក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងពីសមាជិកនៃគណបក្សនយោបាយជាបណ្ដោះអាសន្ន ឬ/និង ដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច។ ប្រធានឬអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត គណៈកម្មការខេត្ត ក្រុងឃុំសង្កាត់រៀបចំការបោះឆ្នោតត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយដូចខាងក្រោមៈ

-សាមីខ្លួនទទួលមរណភាព ។

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរ ។

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

-សាមីខ្លួនប្រព្រឹត្តិផ្ទុយពីបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ការសម្រេចបណ្ដេញចេញពីប្រធានឬអនុប្រធានឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសមត្ថកិច្ចរបស់រដ្ឋសភា ។ ការសម្រេចបណ្ដេញចេញពីប្រធានឬអនុប្រធានឬសមាជិក គណៈកម្មការខេត្ត ក្រុងឃុំសង្កាត់រៀបចំការបោះឆ្នោតជាសមត្ថកិច្ច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-សាមីខ្លួនត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋឬមជ្ឈិមណាមួយ ។ក្នុងករណីដែលមានប្រធានឬអនុទ្រធានឬសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់ពីមុខតំណែងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវដាក់ស្នើបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរដប់(១០)ថ្ងៃទៅគណៈរដ្ឋមន្ត្រី ។រយៈពេលនេះអាចពន្យារដល់សាមសិប(៣០)ថ្ងៃក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។គណៈរដ្ឋមន្ត្រីត្រូវដាក់ស្នើបេក្ខភាពថ្មី ទៅរដ្ឋសភាក្នុងរយៈពេលយ៉ាងយូរប្រាំ (៥)ថ្ងៃ បន្ទាប់ពីបាបទទួលសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ រយៈពេលនេះអាចពន្យារដល់ដប់ប្រាំ(១៥)ថ្ងៃក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។ប្រធានឬអនុប្រធានឬសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានទទួលការតែងតាំងជំនួសកន្លែងដែលទំនេរនេះត្រូវចូលកាន់តំណែងភ្លាម ។ក្នុងករណីដែលមានប្រធាន ឬអនុប្រធាន ឬសមាជិកនៃគណៈកម្មការ ខេត្តក្រុងឃុំសង្កាត់រៀបចំការបោះឆ្នោតបាត់បង់មុខតំណែងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសអ្នកជំនួសតាម បទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៨ថ្មី និងវាក្យខ័ណ្ឌទី១ មាត្រា ២០ថ្មី នៃច្បាប់នេះ ។

## ខ. ការទទួលខុសត្រូវ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទទួលខុសត្រូវធ្វើផែនការរៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងទូទាំងប្រទេស ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។សិទ្ធិអំណាចភារកិច្ចនិងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្មការរៀបចំចាត់ចែងនិងការត្រួតពិនិត្យការបោះឆ្នោតមានដូចតទៅ:

១-ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរីត្រឹមត្រូវយុត្តិធមិ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

២-រៀបចំគំរោងផែនការងារ ថវិកានិងសម្ភារៈបំរើឱ្យការ បោះឆ្នោតផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

៣-តែងតាំងគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការ ការិយាល័យបោះឆ្នោត ។

៤-ធ្វើបទបញ្ជា នីតិវិធីនិងសេចក្តីណែនាំនានាសម្រាប់ដំណើរការ បោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

៥-លើកវិធានការ និងចាត់ចែងការងារដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

៦-ត្រួតពិនិត្យការងាររបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ លំដាប់ថ្នាក់ ។

៧-កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

៨-ចេញសេចក្តីសំរេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ។

៩-ផលិត និងបែងចែកសម្ភារៈ បរិក្ខារបំរើឱ្យការងារបោះឆ្នោត ។

១០-ជ្រើសរើស និងតែងតាំងមន្រ្តីចុះជួយពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតតាមច្បាប់ និងបទបញ្ជា ។

១១-រៀបចំបញ្ជីបោះឆ្នោតនិងសៀវភៅបញ្ជីបោះឆ្នោត ។

១២-ពិនិត្យ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោត ។

១៣-ទទួល និងសំរេចលើពាក្យសុំឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ និងការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្ររបស់គណបក្សនយោបាយ ។

១៤-ត្រួតពិនិត្យ និងសម្របសម្រួលការប្រព្រឹត្តទៅនៃការឃោសនា បោះឆ្នោត ។

១៥-រៀបចំ និងចាត់ចែងការបោះឆ្នោតការរាប់សន្លឹកឆ្នោតការបូកសរុបលទ្ធផលនិងការប្រកាសលទ្ធផល ។

១៦-ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោតឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ ។

ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។

លុបបេក្ខភាពរបស់បេក្ខជន ឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះឡើងវិញ ។

១៧-ត្រួតពិនិត្យចំណូលនិងចំណាយក្នុងពេលឃោសនាបោះឆ្នោតរបស់ បេក្ខជននិងគណបក្សនយោបាយ ។

១៨-ចាត់វិធានការនិងសម្របសម្រួលដើម្បីឱ្យមាន

## ២.គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត

### ក. សមាសភាព

សមាសភាពគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតត្រូវបានតែងតាំងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងចំណោម ប្រជាពលរដ្ឋមន្ត្រីរាជការឬ/និងអ្នកមុខអ្នកការក្នុងខេត្តក្រុងដែលមានសិទ្ធិបោះឆ្នោតលើកលែងតែកងយោធពលខេមរភូមិន្ទនគរបាលជាតិមន្ត្រីតុលាការបព្វជិតសាសនាអភិបាល អភិបាលរងខេត្តក្រុងស្រុកខណ្ឌសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ប្រធានភូមិអនុប្រធានភូមិនិងសមាជិកភូមិ ។សមាសភាពនៃគណៈកម្មការខេត្ត ក្រុងនេះត្រូវមានប្រធានមួយ (១)រូប អនុប្រធានមួយ (១)រូប និងសមាជិកបី(៣)ទៅប្រាំ(៥) រូប ។ គណៈកម្មការខេត្តក្រុងនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ។ក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត គណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យមន្ត្រីលេខាធិការដ្ឋានមួយ (១)រូប ឬពីរ(២)រូប ដើម្បីបន្តនិរន្តរភាពការងារបោះឆ្នោតនៅតាមខេត្តក្រុង ។

### ខ. ភារកិច្ច និងការទទួលខុសត្រូវ

ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការ បោះឆ្នោតមានដូចតទៅ

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ញានិងលិខិតបទដ្ឋាននានាអនុញ្ញាតឬតម្រូវឱ្យអនុវត្ត ។

២-អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យ ។

## ៣.គណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត

### ក. សមាសភាព

សមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមសំណើររបស់គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតក្នុងចំណោមប្រជាពលរដ្ឋមន្ត្រីរាជការឬ/និងអ្នកមុខអ្នកការក្នុងស្រុក

ខណ្ឌឃុំសង្កាត់ដែលមានសិទ្ធិបោះឆ្នោតលើកលែងតែកងយោធពលខេមរភូមិន្ទនគរបាលជាតិមន្ត្រីតុលាការបព្វជិតសាសនាអភិបាល អភិបាលរងស្រុកខណ្ឌសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានភូមិអនុប្រធានភូមិនិងសមាជិកភូមិ ។សមាសភាពគណៈកម្មការនេះមានប្រធានមួយ(១)រូប អនុប្រធានមួយ (១)រូប និង សមាជិកបី(៣)រូប ។

### ខ. ភារកិច្ច និងការទទួលខុសត្រូវ

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមានភារកិច្ច និងការទទួលខុសត្រូវដូចតទៅ

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជានិងលិខិតបទដ្ឋាននានាអនុញ្ញាតឬតម្រូវឱ្យអនុវត្ត ។

២-អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មធិការជាតិរៀប ចំការបោះឆ្នោតប្រគល់ឱ្យ ។

## ៤. គណៈកម្មការការិយាល័យបោះឆ្នោត

### ក. សមាសភាព

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោតត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមសំណើររបស់ គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតក្នុងចំណោមប្រជាពលរដ្ឋមន្ត្រីរាជការក្នុងស្រុកខណ្ឌឃុំសង្កាត់ដែលមានសិទ្ធិបោះឆ្នោតលើកលែងតែកងយោធពលខេមរភូមិន្ទនគរបាលជាតិមន្ត្រីតុលាការបព្វជិតសាសនាអភិបាល អភិបាលរងស្រុកខណ្ឌសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ មន្ត្រីដែលបំរើការងាររដ្ឋបាលក្នុងសាលាឃុំសង្កាត់ ប្រធានភូមិអនុប្រធានភូមិនិងសមាជិកភូមិ ។សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រធានមួយ(១)រូប អនុប្រធានមួយ (១)រូប លេខាធិការមួយ (១)រូប និងសមាជិកពីរ(២)រូប តាមការចំបាច់ និងការកំណត់របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### ខ. ភារកិច្ច និងការទទួលខុសត្រូវ

ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការការិយាល័យ បោះឆ្នោតមានដូចតទៅ

១-អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជានិងលិខិតបទដ្ឋាននានាអនុញ្ញាតឬតម្រូវឱ្យអនុវត្ត ។

២-អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មធិការជាតិរៀប ចំការបោះឆ្នោតប្រគល់ឱ្យ ។

២-ការចុះបញ្ជីគណបក្សនយោបាយ

ក-ការចុះបញ្ជីគណបក្សនយោបាយ

## ផ្នែកទី២. ជាបេក្ខជនគណបក្សនយោបាយ

### ១.លក្ខខណ្ឌកំណត់

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រត្រូវបំពេញល័ក្ខខណ្ឌដូចខាងក្រោម

១-មានសញ្ជាតិខ្មែរពីកំនើត ។

២-មានអាយុម្ភៃប្រាំ (២៥) ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត។

៣-មានសិទ្ធិបោះឆ្នោតនិងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៤-មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥-មានការតែងតាំងពីគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ។

## ២_ការចុះបញ្ជីគណបក្សនយោបាយ

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមកៅសិប (៩០) ថ្ងៃមុនថ្ងៃបោះឆ្នោត ។ដើម្បីចុះបញ្ជីចុះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្តជាផ្លូវការគណបក្សនយោបាយត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមបែបបទកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងយូរចិតសិប (៧០) ថ្ងៃមុនថ្ងៃបោះឆ្នោតដោយភ្ជាប់ មកជាមួយ

១-សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីចុះគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃមួយច្បាប់ ។

២-ឈ្មោះគណបក្សនយោបាយជាអក្សរកាត់និងសញ្ញាសម្គាល់ គណបក្សនយោបាយ ។

៣-អាស័យដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ ។

៤-បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស ។បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិចមួយភាគបី (១/៣) នៃចំនួនអាសនៈក្នុងរដ្ឋសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ ។

៥-ឈ្មោះមណ្ឌលដែលគណបក្សនយោបាយមានបំណងទៅឈរឈ្មោះតាមមណ្ឌលទាំងនោះ ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលត្រូវមានចំនួនបេក្ខជន គ្រប់តាមចំនួនកំណត់អាសនៈ និងតាមគំរូដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តល់ឱ្យ ។ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈមួយ (១) ឬពីរ (២) ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិចបី (៣)រូប ។

៦-សេចក្តីប្រកាសអំពីគណនីធនាគារដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗរួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយនៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

៧-លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ពីការ បង្កើតគណបក្សនយោបាយ ។

៨-សេចក្តីប្រកាសរបស់គណបក្សនយោបាយសន្យាថាចូលរួមបោះឆ្នោតនិងទទួលយកលទ្ធផលនៃការបោះឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ និងចូលរួមអនុវត្តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្តក្រមសីលធម៌ និងច្បាប់ស្តីពីគណបក្សនយោបាយ ។

៩-បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ ។

១០-បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួនដប់ប្រាំលាន (១៥000000) រៀលដែលចេញដោយរតនាគារជាតិ ។ ប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយបានវិញក្នុងករណីដែលគណបក្សនយោបាយនោះបានទទួលសន្លឹកឆ្នោតយ៉ាងតិចបីភាគរយ (៣%) នៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈមួយក្នុងរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវប្រព្រឹត្តិទៅក្នុងរយះពេលដប់ (១០) ថ្ងៃ គិតពីថ្ងៃប្រកាសរំលាយរដ្ឋសភា ។

## ផ្នែកទី៣. ការបោះឆ្នោតនិងការដោះស្រាយបណ្ដឹង

### ១.ដំណើរការបោះឆ្នោត

ការិយាល័យបោះឆ្នោតត្រូវរៀបចំតាមការកំណត់ដូចដូចមានចែងក្នុងមាត្រា៩៥ថ្មី និងមាត្រា៩៦ថ្មីនៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ជ្រើសតាំងតំណាងរាស្ត្រ។ ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃប៉ុណ្ណោះការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោងប្រាំពីរព្រឹករហូតដល់ម៉ោងដប់ប្រាំលើកលែងតែមានសេចក្ដីសម្រេចផ្សេងពីនេះរបស់ គណៈកម្មាធិការជាតិរៀបចំ
ការបោះឆ្នោត។ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយគណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោងដប់ប្រាំ។ប្រធានការិយាល័យបោះឆ្នោតត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោងដប់ប្រាំជនគ្រប់រូបដែលមានបំណងបោះឆ្នោតមិនត្រូវអនុញ្ញាតឲ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោងដប់ប្រាំឡើយ។ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោងដប់ប្រាំហើយអាចអនុញ្ញាតឲ្យបោះឆ្នោតគឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោតឬក្នុងបរិវេណខាងក្នុងនៅម៉ោងដប់ប្រាំ។គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោតហើយត្រូវបិទផ្សាយបញ្ជីទាំងនេះនៅគ្រប់ការិយាល័យបោះឆ្នោតសាមសិបថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត។គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតអាចសុំសេចក្ដីចម្លងនៃបញ្ជីឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោតនេះបានដោយបង់ថ្លៃ។តម្លៃនេះគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ជូនការិយាល័យបោះឆ្នោតនីមួយៗនូវសម្ភារៈដូចតទៅតាមចំនួនសមស្របមួយថ្ងៃមុនថ្ងៃបោះឆ្នោត។

១. បញ្ជីបោះឆ្នោត។

២. សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់។

៣. ហិបបោះឆ្នោត។

៤. បន្ទប់សម្ងាត់។

៥. ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត។

៦. ទឹកជ្រលក់សម្រាប់សម្គាល់ថាបានបោះឆ្នោតហើយ។

៧. សោនិងប្រដាប់ឃ្លុំ។

៨. ក្រដាសបែបបទសម្រាប់បំពេញកំណត់ហេតុនិងសម្រង់លទ្ធផល។

៩. ប៊ិចសរសេរដែលមានគុណភាពល្អ។

១០. ស្រោមសំបុត្រដែលបោះត្រាលើខ្នងរួចហើយ។

១១. ថង់ប្លាស្ទិក។

១២. សម្ភារៈនិងបរិក្ខារចាំបាច់ផ្សេងៗទៀត។

មុនថ្ងៃបោះឆ្នោតមួយថ្ងៃប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវប្រជុំសមាជិកទាំងអស់ដើម្បីត្រួតពិនិត្យវត្តមានសមជិកនិងពិនិត្យទីតាំងការិយាល័យបោះឆ្នោតនិងពិនិត្យសម្ភារៈបរិក្ខារបំរើឲ្យការងារបោះឆ្នោត។ប្រសិនបើមានសមាជិកណាម្នាក់អវត្តមានសមាជិកនោះត្រូវជំនួសដោយសមាជិកថ្មីដែលជ្រើសតាំងឡើងស្របតាមបទប្បញ្ញត្តិដែលចែងក្នុងបទបញ្ជានិងនីតិវិធី។ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ការដើម្បីឲ្យការិយាល័យបោះឆ្នោតមានសម្ភារៈបរិក្ខារនិងសង្ហារិមចាំបាច់សម្រាប់ការបោះឆ្នោត។ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោតហើយចាត់វិធានការការពារសន្តិសុខប្រសិនបើចាំបាច់។នៅថ្ងៃបោះឆ្នោតសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតត្រូវមកដល់ទីតាំងការិយាល័យបោះឆ្នោតដើម្បីរៀបចំការបោះឆ្នោតមួយម៉ោងយ៉ាងតិចមុនចាប់ផ្តើមការបោះឆ្នោតគណៈកម្មការការិយាល័យបោះឆ្នោតត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃតំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍មុននឹងអនុញ្ញាតឲ្យអ្នកទាំងនេះចូលក្នុងការិយាល័យបោះឆ្នោត។មុននឹងចាប់ផ្តើមការបោះឆ្នោតប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវបើកបង្ហាញហិបឆ្នោតនៅចំពោះមុខសមាជិកគណៈកម្មការតំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ទាំងអស់ថាគ្មានអ្វីនៅក្នុងហិបឆ្នោតទេរួចចាក់សោនិងកត់លេខឃ្លុំដែលចាក់នេះក្នុងកំណាត់ហេតុនៃការបោះឆ្នោតបន្ទាប់មកត្រូវពិនិត្យនិងរាប់សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ដែលបានទទួលជាក់ស្តែងព្រមទាំងបើកស្រោមសំបុត្រដែលមានត្រាសសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។ប្រជាពលរដ្ឋម្នាក់ៗត្រូវបោះឆ្នោតតែនៅការិយាល័យបោះឆ្នោតដែលឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតនិងត្រូវបានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន។សមាជិកនៃគណៈកម្មធិការការិយាល័យបោះឆ្នោតត្រូវបានអញ្ជើញឲ្យបោះឆ្នោតមុនគេបន្ទាប់មកតំណាងគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតនោះ។អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិតែមួយសន្លឹក

និងតែមួយដងគត់ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់។អ្នកបោះឆ្នោតម្នាក់ៗត្រូវបោះឲ្យគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្តដោយគូសសញ្ញាយកតែគណបក្សនយោបាយមួយនិងមិនត្រូវកែដូរឬបន្ថែមបន្ថយទេ។របៀបបោះឆ្នោតលម្អិតផ្សេងទៀតត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ការបោះឆ្នោតជាការសម្ងាត់ឬការបង្ហើបការសម្ងាត់តាមរូបភាពណាត្រូវហាមឃាត់។ដើម្បីរក្សារប្រៀបរយក្នុងបន្ទប់បោះឆ្នោតជនម្នាក់ៗត្រូវគោរពតាមបទបញ្ជានៃការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ចំពោះប្រជាពលរដ្ឋពិការដែលពុំអាចបោះឆ្នោតដោយខ្លួនឯងបានមានសិទ្ធជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយឬមានសិទ្ធសុំជំនួយពីប្រធានការិយាល័យបោះឆ្នោត។ប្រជាពលរដ្ឋដែលមានតែឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនតែពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោតពុំអាចបោះឆ្នោតបានឡើយ។អាចចូលបានក្នុងការិយាល័យបោះឆ្នោតតែអ្នកត្រូវបោះឆ្នោតលើកលែងតែមានការអនុញ្ញាតពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ហាមដាច់ខាតមិនឲ្យយកអាវុធឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃកាយាល័យបោះឆ្នោតនិងហាមមិនឲ្យស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោតលើកលែងតែមានការអនុញ្ញាតិពិសេសពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ទីធ្លាការិយាល័យបោះឆ្នោតត្រូវមានទំហំប្រមាណ២០០០ម៉ែត្រការ៉េហើយរង្វង់ការពារសន្តិសុខត្រូវស្ថិតនៅចំងាយប្រមាណ២០០ម៉ែត្រជុំវិញការិយាល័យបោះឆ្នោតលើកលែងតែមានការសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ក្នុងករណីដែលគណបក្សនយោបាយបានយល់ឃើញថាការបោះឆ្នោតមិនប្រក្រតីតំណាងគណបក្សនយោបាយនោះអាចប្ដឹងជំទាស់ឬតវ៉ាមកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតបាន។របៀបបែបបទប្ដឹងជំទាស់ឬតវ៉ាត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធី។គណៈកម្មការការិយាល័យបោះឆ្នោតត្រូវ

ដោះស្រាយបណ្ដឹងជំទាស់ឬតវ៉ានេះ។ការសម្រេចរបស់គណៈកម្មការការិយាល័យបោះឆ្នោតជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួនប្រសិនបើការបោះឆ្នោតនោះប្រព្រឹត្តទៅដោយប្រក្រតី។ប្រសិនបើអ្នកតំណាងនោះនៅតែជំទាស់ឬតវ៉ាគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះបណ្ដឹងជំទាស់ឬតវ៉ានេហក្នុងកំណាត់ហេតុដោយឲ្យអ្នកជំទាស់ឬតវ៉ានោះចុហត្ថលេខាជាមួយ។ក្រោយពីការប្រកាសបញ្ចប់ការបោះឆ្នោតគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះក្នុងកំណាត់ហេតុនូវចំនួនអ្នកដែលបានមកបោះឆ្នោតនិងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើប្រាស់ហើយត្រូវរៀបចំដើម្បីរាប់សន្លឹកឆ្នោតនូវនឹង

កន្លែងស្របតាមបទបញ្ជានិងនិតីវិធី។ចំពោះការិយាល័យបោះឆ្នោតដែលមិនអាចរៀបចំរាប់សន្លឹកឆ្នោត

ពួនូវការិយាល័យបោះឆ្នោតរបស់ខ្លួនបានដោយករណីប្រធានសក្តិឬអសន្តិសុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងធ្វើការនៃនាំដោយឡែក។អ្នកសង្កេតជាតិនិងអន្តរជាតិព្រមទាំងអ្នកតំណាងគណបក្សនយោបាយនីមួយៗអាចចូលរួមជាសាក្សីក្នុងការរាប់សន្លឹកឆ្នោតនេះគណៈការិយាល័យបោះឆ្នោតត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោត។មុននឹងបើកហិបឆ្នោតប្រធានគណៈកម្មាធិការិយាល័យបោះឆ្នោតត្រូវអញ្ជើញសមាជិនគណៈកម្មការការិយាល័យបោះឆ្នោតតំណាងគណបក្សនយោបាយនិងសង្កេតការណ៍ពិនិត្យសោឃ្លុំហើយ

បើកហិបឆ្នោតនៅចំពោះមុខអ្នកទាំងនោះ។គណៈកម្មការការិយាល័យបោះឆ្នោតត្រូវរាប់ចំនួនសន្លឹកឆ្នោតដែលមាននៅក្នុងហិបឆ្នោតហើយផ្ទៀងផ្ទាត់ចំនួនអ្នកដែលមានបានមកបោះឆ្នោតដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត។ក្នុងករណីដែលសន្លឹកឆ្នោតក្នុងហិបឆ្នោតមានចំនួនខុសគ្នានឹងចំនួនអ្នកដែលបោះឆ្នោតប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ឲ្យរាប់ឡើងវិញ។ប្រសិនបើចំនួនខុសគ្នានៅតែមានដដែលប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះក្នុងកំណាត់ហេតុ។ បន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ឲ្យរាប់សន្លឹកឆ្នោតដោយអនុលោមបទបញ្ជានិងនិតិវិធីត្រូវចាត់ទុកជាបានការសន្លឹកឆ្នោតណាដែលមានគូសសញ្ញាគាំទ្រគណបក្សនយោបាយតែមួយនៅលើសន្លឹកឆ្នោតដែលគណៈកម្មការការិយាល័យបោះឆ្នោតចែកឲ្យ។

ត្រូវទុកជាមោឃៈសន្លឹកឆ្នោតៈ

១. ដែលពុំមែនជាសន្លឹកឆ្នោតត្រូវការ

២.ដែលគ្មានគំនូសឬមានគំនូសតែគណៈកម្មការការិយាល័យបោះឆ្នោតពុំអាចសន្និដ្ឋានបានថាបោះឲ្យគណបក្សនយោបាយណាមួយ

៣. ដែលមានសញ្ញាដែលនាំឲ្យគេស្គាល់អ្នកបោះឆ្នោត

៤. ដែលមានរហែកឬខូច

៥. ដែលគ្មានត្រាសម្ងាត់ជាផ្លូវការ។

សន្លឹកឆ្នោតដែលទុកជាមោឃៈក្នុងចំណុច១ដល់៥ខាងលើនេះត្រូវកំណាត់ដោយបទបញ្ជានិងនិតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។បន្ទាប់ពីបានរាប់សន្លឹករួច

ហើយគណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោតនេះជាពីរច្បាប់មួយច្បាប់ផ្ញើជូនគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោតសន្លឹកឆ្នោតបានការពុំបានការសន្លឹកឆ្នោតដែលពុំបានប្រើប្រាស់បណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាននឹងឯកសារផ្សេងៗទៀតនិងមួយច្បាស់ទៀតបទនៅការិយាល័យបោះឆ្នោត។សន្លឹកឆ្នោតបានការពុំបានការសន្លឹកឆ្នោតពុំបានប្រើប្រាស់ពាក្យបណ្តឹងជំទាស់ឬតវ៉ាឯកសារផ្សេងៗត្រូវច្រកដោយឡែកពីគ្នាក្នុងស្រោមសំបុត្រដែលបានចែកឲ្យ។កំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោតនេះត្រូវចុះហត្ថលេខាដោយប្រធាននិងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត។តំណាងគណបក្សនយោបាយអាចចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះបាន។ការបញ្ជូនការប្រគល់និងការទទួលកំណត់ហេតុត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធី។តំណាងគណបក្សនយោបាយអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិចូលរួមជាសាក្សីក្នុងការប្រគល់ឬការទទួលកំណត់ហេតុបោះឆ្នោត។ គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតត្រូវប្រមូលកំណាត់ហេតុនិងឯកសារទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោតរួចធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំសង្កាត់របស់ខ្លួន។កំណត់ហេតុនេះត្រូវធ្វើជាបួនច្បាប់មួយច្បាប់ផ្ញើជូនគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតមួយច្បាប់បិទផ្សាយនៅទីស្នាក់ការគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតនិងមួយច្បាប់ទៀតទុកជាឯកសារ។ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោតឬពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតណាមួយគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតត្រូវបើកការប្រជុំសម្រេចជាសាធារណៈជាបន្ទាន់។ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតអ្នកប្តឹងតវ៉ាឬមានសិទ្ធប្តឹងតវ៉ាទៅគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតជាបន្ទាន់។គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតត្រូវប្រមូលកំណត់ហេតុទាំងអស់ពីគ្រប់គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតរួចធ្វើកំណត់ហេតុសរុបពីលទ្ធផលនៃការបោះឆ្នោតក្នុងខេត្តក្រុងរបស់ខ្លួន។កំណត់ហេតុនេះត្រូវធ្វើជាបីច្បាបមួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយភ្ជាប់ទៅជាមួយបញ្ជីបោះឆ្នោតសន្លឹកឆ្នោតបានការសន្លឹកឆ្នោតមិនបានការសន្លឹកឆ្នោតពុំបានប្រើប្រាស់ពាក្យបណ្តឹងជំទាស់ឬតវ៉ាប្រសិនបើមានព្រមទាំងឯកសារផ្សេងៗទៀតមួយច្បាប់បិទនៅទីស្នាក់ការគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតនិងមួយច្បាប់ទៀតទុកជាឯកសារ។ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោតឬអំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតត្រូវធ្វើសវនាការជាសាធារណៈដើម្បីសម្រេចអំពីបណ្តឹងតវ៉ាទាំង

នោះជាបន្ទាន់រួចហើយត្រូវផ្ញើសេចក្ដីសម្រេចរបស់ខ្លួនភ្ជាប់ជាមួយនឹងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោតជូនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ក្នុងករណីអ្នកប្ដឹងតវ៉ា
ពុំពេញចិត្តនឹងសេចក្ដីសម្រេចរបស់គណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតអ្នកប្ដឹងតវ៉ាឬតំណាងត្រូវធ្វើការប្ដឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាបន្ទាន់។គណៈកម្មាធិការរៀបចំការបោះឆ្នោតត្រូវធ្វើការពិនិត្យនិងសម្រេចថាយកលទ្ធផលនៃការបោះឆ្នោតនេះជាបានការឬឲ្យបោះឆ្នោតសាជាថ្មី។ការបោះឆ្នោតសារជាថ្មីត្រូវធ្វើឡើងក្នុងរយៈពេលប្រាំបី(៨)ថ្ងៃយ៉ាងយូរបន្ទាប់ពីការសម្រេចនេះ។គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រមូលលទ្ធផលទាំងអស់មកពិនិត្យហើយធ្វើការសម្រេចលើលទ្ធផលបោះឆ្នោត។បើភាពមិនប្រក្រតីមិនធ្ងន់ធ្ងរទេគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រកាសទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។ប្រសិនបើភាពមិនប្រក្រតីមានកម្រិតធ្ងន់ធ្ងរធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ប្រសិនបើភាពមិនប្រក្រតីមានកម្រិតធ្ងន់ធ្ងរធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនោះឬនៅការិយាល័យបោះឆ្នោតទាំងនោះហើយជូនព័ត៌មានដល់គណបក្សនយោបាយ។ក្នុងករណីនេះការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះឬនៅការិយាល័យបោះឆ្នោតទាំងនោះត្រូវធ្វើប្រាំបីថ្ងៃយ៉ាងយូរបន្ទាប់ពិការសម្រេចនេះ។ក្រោយពីការត្រួតពិនិត្យនិងសម្រេចលើលទ្ធផលនៃការបោះឆ្នោតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ លទ្ធផល
បណ្ដោះអាសន្ននេះត្រូវផ្ញើមួយច្បាប់ថ្វាយព្រះមហាក្សត្រនិងមួយច្បាប់ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ។គណបក្សនយោបាយដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិសុំសេចក្ដីចម្លងលទ្ធផលបណ្ដោះអាសន្ននេះបាន។

**២. ការដោះស្រាយបណ្ដឹង**

បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្ដោះអាសន្នក្នុងរយៈពេល៧២ម៉ោងយ៉ាងយូរគ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតអាចប្ដឹងតវ៉ាអំពីលទ្ធផលមួយផ្នែកឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឬទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បានដោយបញ្ជាក់ភាពមិនប្រក្រតីរបស់គណៈកម្មការឬសមាជិកគណៈកម្មការដែលធ្វើខុសពីកាលបរិច្ឆេទដែលធ្វើខុសពីកន្លែងដែលមាន

ការប្រព្រឹត្តខុសពីឈ្មោះនិងអាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារឬភស្តុតាងដទៃទៀត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលសែសិបប្រាំបីម៉ោងយ៉ាងយូបន្ទាប់ពីបានទទួលពាក្យបណ្ដឹង។ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចថាបណ្ដឹងតវ៉ាពុំអាចទទួលបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវៈ

- បំពេញបែបបទនៃការបដិសេធដោយបញ្ជាក់ពីមូលហេតុនិងកាលបរច្ឆេទនៃការបធិសេធ។
- ផ្ដល់សេចក្ដីចម្លងនៃសេចក្ដីបធិសេធមួយច្បាប់ទៅអ្នកប្ដឹងតវ៉ាឬ/និងទៅគណបក្សនយោបាយ។

## ជំពូក២. ប្រព័ន្ធច្បាប់បោះឆ្នោតប្រទេសថៃ[2]

### ផ្នែកទី១. ទិដ្ឋភាពនៃច្បាប់ស្ដីពីការបោះឆ្នោតសភាតំណាងរាស្រ្ត

### ១. ទិដ្ឋភាពពាក់ព័ន្ធនៃច្បាប់

ច្បាប់រៀបចំអង្គការស្ដីពីការបោះឆ្នោត របស់ជ្រើសរើសសមាជិក នៃសភាតំណាង និងសមាជិកព្រឹទ្ធសភានេះវាត្រូវបានអនុម័តដោយព្រះមហាក្សត្រហើយជាមួយនឹងការយល់ព្រម របស់ រដ្ឋសភា ច្បាប់ នេះត្រូវបាន គេហៅថាច្បាប់ស្ដីពីការ "ជ្រើសតាំង សមាជិកនៃសភាតំណាងនិងព្រឹទ្ធសភា" ឆ្នាំ១៩៩៨បទបញ្ញត្តិខាងក្រោមយើយត្រូវមានអានុ ភាពនិរាករណ៍នូវច្បាប់ដូចខាងក្រោមនេះៈ

- ច្បាប់ការបោះឆ្នោតជាសមាជិក នៃ សភាតំណាងឆ្នាំ១៩៧៩
- ច្បាប់ការបោះឆ្នោតជ្រើសរើស សមាជិក សភា តំណាងឆ្នាំ១៩៧៩
- អនុក្រឹត្យ ស្ដីពីវិសោធនកម្មបន្ទាន់ ការបោះឆ្នោតជ្រើសរើស សមាជិក នៃ សភាតំណាង លេខ (BE) ២៥២២ ឆ្នាំ ១៩៧៩, លេខ ២៥២៦ ឆ្នាំ១៩៨៣
- អនុក្រឹត្យ ស្ដីពីវិសោធនកម្ម បន្ទាន់ ការបោះឆ្នោតជ្រើសរើស សមាជិក នៃ សភាតំណាង លេខ ២៥២២ ឆ្នាំ១៩៧៩ (លេខ២), លេខ ២៥២៩ ឆ្នាំ១៩៨៦
- ច្បាប់ការបោះឆ្នោតជ្រើសរើស សមាជិក សភា តំណាងឆ្នាំ១៩៩២
- អនុក្រឹត្យ ស្ដីពីវិសោធនកម្ម សង្គ្រោះបន្ទាន់ ការបោះឆ្នោតជ្រើសរើស សមាជិក នៃ សភាតំណាងលេខ ២៥២២ ឆ្នាំ១៩៧៩ (លេខ៣), លេខ ២៥៣៨ ឆ្នាំ១៩៩៥

### ២. ពាក្យគន្លឹះ

" **អ្នកបោះឆ្នោត**"មានន័យថាអ្នកមានសិទ្ធិបោះឆ្នោត

[2]ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តនៃការបោះឆ្នោតសភាតំណាងរាស្រ្ត(ថៃ) ឆ្នាំ១៩៩៨

**" បេក្ខជន"**មានន័យថា ជាបេក្ខជន សម្រាប់ការ បោះឆ្នោត របស់សភាតំណាង ឬ បេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើស សមាជិកព្រឹទ្ធសភា

**"ថ្ងៃ បោះឆ្នោត"**គឺជាថ្ងៃថេរសម្រាក់ការបោះឆ្នោត

**"ស្ថានីយ៍បោះឆ្នោត"**មានន័យថា តំបន់ ដែលបានកំណត់ សម្រាប់គោលបំណង បោះឆ្នោត"

**កន្លែង ការិយាល័យបោះឆ្នោត"**មានន័យថាជា កន្លែង ដែលបានកំណាសម្រាប់គោលបំណងបោះឆ្នោត និងត្រូវរួមបញ្ចូលនូវតំបន់ដែលបានបញ្ជាក់នៅក្បែរកន្លែងបោះឆ្នោតមួយ

**"រដ្ឋបាល ក្រុងបាងកក Changwat "**រួមបញ្ចូលខេត្តស្រុក និងឃុំ

**"ការិយាល័យ កណ្តាល Changwat "**រួមបញ្ចូលទាំង ការិយាល័យ រដ្ឋបាល ក្រុងបាងកក

## ផ្នែកទី២. នីតិវិធីមុនបោះឆ្នោត

### ១. សមាជិកសភាតំណាង

#### ក.បញ្ញត្តិទូទៅ

នៅក្នុងការបោះឆ្នោតទូទៅនៃសមាជិកសភាតំណាងគណៈកម្មការរៀបចំការបោះឆ្នោតត្រូវកាន់គោលការណ៍បោះឆ្នោតដូចខាងក្រោមៈ

(១)សមាជិកនៃសភាតំណាងគឺជាតំណាងឲ្យមណ្ឌលបោះឆ្នោតរបស់ខ្លួន

(២) សមាជិកនៃសភាតំណាងគឺត្រូវផ្អែកលើមូលដ្ឋាននៃបញ្ជីបេក្ខជនគណបក្សដែលរៀបចំដោយគណបក្សនយោបាយ។

បន្ទាប់ពីការ ប្រកាសឱ្យប្រើ ព្រះរាជក្រឹត្យស្តីពី ការបោះឆ្នោតនៃ សមាជិកនៃ សភាតំណាងគណៈកម្មការរៀបចំការបោះឆ្នោតត្រូវបោះពុម្ពផ្សាយពិសេសគឺទាក់ទងទៅនឹងការបោះឆ្នោតដូចខាងក្រោមនេះៈ

(១) កាលបរិច្ឆេទនៃការដាក់បេក្ខភាពនៅក្នុងការបោះឆ្នោតមិនត្រូវយឺតជាង ម្ភៃ ថ្ងៃចាប់ពីថ្ងៃព្រះរាជក្រឹត្យចូលជាធរមាន

(២)កាលបរិច្ឆេទនៃការដាក់ស្នើនៃបញ្ជីគណបក្សមួយនៅក្នុងការបោះឆ្នោតនឹងត្រូវធ្វើមុនពេលកាលបរិច្ឆេទនៃការដាក់បេក្ខភាពនៅក្នុងការបោះឆ្នោត

(៣)ចំនួនសមាជិកនៃសភាតំណាងនៅក្នុងការបោះឆ្នោតនឹងត្រូវកំណត់ចំនួនជាក់លាក់

(៤) ចំនួនមណ្ឌល ដែលមាននៅក្នុងខេត្តនីមួយៗ សេចក្តីលម្អិតនៃ ស្រុក និងឃុំនៅក្នុងមណ្ឌនីមួយៗត្រូវបានបញ្ជាក់។ក្នុងករណីដែលមានការប្រកាសឱ្យប្រើប្រាស់ព្រះរាជក្រឹត្យពីការបោះឆ្នោត។

**ខ.មណ្ឌលបោះឆ្នោត/ការិយាល័យបោះឆ្នោត**

គណៈកម្មការរៀបចំការបោះឆ្នោតត្រូវ បោះពុម្ពផ្សាយ នៅក្នុងដែនរដ្ឋបាលនៃ ការបោះឆ្នោតនេះនៅក្នុងខេត្តជាកន្លែងដែលចំនួនសមាជិកនៃសភាតំណាងត្រូវបានជាប់ឆ្នោត។ គណៈកម្មមាធិការរៀបចំការបោះឆ្នោតត្រូវបែងចែកសន្លឹកឆ្នោត បញ្ជីបោះឆ្នោត និងមណ្ឌលបោះឆ្នោតក្នុងករណីមណ្ឌលនេះមានលើសពីមួយក្នុងខេត្តគណៈកម្មាធិការបោះឆ្នោតនៃមណ្ឌលបោះឆ្នោត តែងតាំងដោយគណៈកម្មការ រៀបចំការបោះឆ្នោតដោយពិចារណាភាពងាយស្រួលដល់អ្នកបោះឆ្នោតនិងយោងតាមករណីដូចខាងក្រោម៖

(១) ឃុំនឹងត្រូវមានស្ថានីយ៍ បោះឆ្នោតមួយ លើកលែងតែនៅក្នុងតំបន់នៃ ក្រុង រដ្ឋបាលក្រុងបាងកក ក្រុង, តំបន់ មានប្រជាជនច្រើនជាដើម។

(២) ចំនួន ប្រមាណ ប្រាំបីរយអ្នកនៃអ្នកបោះឆ្នោតនឹងត្រូវបានប្រើជាលក្ខណៈវិនិច្ឆ័យការជូនដំណឹងបញ្ជាក់ពីការឲ្យ មានស្ថានីយ៍បោះឆ្នោតមួយហើយត្រូវបានធ្វើឡើងមិនតិចជាងម្ភៃថ្ងៃមុនថ្ងៃបោះឆ្នោតដោប្រកាស ជូនដំណឹងបែបនេះនៅការិយាល័យ កណ្តាលខេត្តស្រុក និងត្រូវធ្វើផែនទីគ្រោងបង្ហាញព្រំដែននៃស្ថានីយ៍បោះឆ្នោតនោះ។ការផ្លាស់ប្តូរព្រំដែននៃស្ថានីយ៍បោះឆ្នោតមួយអាចត្រូវបានធ្វើឡើងដោយផ្តល់ការជូនដំណឹង មិនតិចជាងដប់ថ្ងៃមុនពេលថ្ងៃបោះឆ្នោតឬអាចតិចជាងនេះក្នុងករណីមានអាសន្ន។ កន្លែងបោះឆ្នោតនៅក្រោមករណីខាងលើគឺជាកន្លែងដែល អាចធ្វើដំណើរបាន យ៉ាងងាយស្រួលដោយ សាធារណៈសម្រាប់ការបោះឆ្នោតហើយត្រូវមានសញ្ញាបង្ហោះតាមបរិវេណដោយអនុលោមតាមលក្ខខណ្ឌភូមិសាស្រ្តនៃតំបន់នេះ។

**គ.មន្រ្តីបោះឆ្នោត**

នៅក្នុងការបោះឆ្នោតសមាជិកសភាតំណាងគណៈកម្មការរៀបចំការបោះឆ្នោត ត្រូវមានអំណាចដើម្បី តែងតាំង មនុស្សដើម្បី បំរើការជាមន្រ្តីបោះឆ្នោត ដូចខាងក្រោម៖

(១) ប្រធានមណ្ឌលបោះឆ្នោត មាន ភារកិច្ចទាក់ទងទៅនឹង កម្មវិធី សម្រាប់ បេក្ខភាពនៃការ បោះឆ្នោត មួយ នៅក្នុងមណ្ឌលនោះ

(២)សមាជិកនៃគណៈកម្មាធិការបោះឆ្នោតនៃមណ្ឌលមានមិនតិចជាងប្រាំបួននាក់ដែលមានភារកិច្ចទាក់ទង នឹងការគ្រប់គ្រងទៅស្ថានីយ៍បោះនិងរាប់សន្លឹកឆ្នោតការលុបឈ្មោះនៅក្នុងមណ្ឌលរួមទាំងកាតព្វកិច្ចដើម្បីត្រួតពិនិត្យការបោះឆ្នោតការរាប់សម្លេងឆ្នោតនិង ការប្រកាសពីលទ្ធផលនៃការបោះឆ្នោត។ប្រធាននៃ គណៈកម្មាធិការបោះឆ្នោតនៃមណ្ឌលត្រូវតែតាំងអនុគណៈកម្មាធិឬក្រុមមួយដើម្បីជួយនៅក្នុងការងារបោះឆ្នោត គណៈកម្មាធិការបោះឆ្នោតនៃមណ្ឌលបោះឆ្នោតតែងតាំងមន្រ្តីបោះឆ្នោតដូចខាងក្រោម៖

(១) គណៈកម្មាធិ ការ ស្ថានីយ៍ បោះឆ្នោតមួយ ដែលមានសមាសភាពរបស់សមាជិក មិនតិចជាងប្រាំពីរនាក់មានភារកិច្ចទាក់ទងទៅនឹងបោះឆ្នោតនៅ ក្នុងស្ថានីយ៍បោះឆ្នោតនីមួយៗ

(២) គណៈកម្មការរាប់សន្លឹកឆ្នោតមានសមាជិកសមស្របមានកាតព្វកិច្ចរាប់សន្លឹកឆ្នោតដើម្បីផ្តល់សុវត្ថិភាគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតត្រូវតែងតាំងមន្ត្រីរដ្ឋម្នាក់មានកាតព្វកិច្ចរក្សាសុវត្ថិភាពនៃការបោះឆ្នោតគណៈកម្មាធិការ ស្ថានីយ៍ បោះឆ្នោតត្រូវ មានប្រធាន មួយនិងសមាជិក ពីរនាក់ទៀត តែងតាំងដោយ គណៈកម្មាធិ ការមណ្ឌលបោះឆ្នោតនិង តំណាងនៃគណបក្សនយោបាយដែលបានតែងតាំងសមាជិករបស់ខ្លួននៅក្នុងមណ្ឌលបោះ។នៅថ្ងៃបោះឆ្នោតនៅពេលចាប់ផ្តើមបោះឆ្នោតប្រសិនបើសមាជិកតិចជាងប្រាំពីរនៃគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតមួយមកដើម្បីបំពេញកាតព្វកិច្ចរបស់ពួកគេគណៈកម្មាធិការ បោះឆ្នោតនៃស្ថានីយ៍បោះឆ្នោតដូចនឹងតែងតាំងបេក្ខជនមួយនៅក្នុងមណ្ឌលបោះឆ្នោតដូចជាសមាជិកបន្ថែមដើម្បីបំពេញតាមចំនួននៃសមាជិកទាំងប្រាំពីរនេះ។

## ២. អំពីអ្នកបោះឆ្នោត និងការចំណាយឃោសនាបោះឆ្នោត

### ក. អ្នកបោះឆ្នត និងតួនាទី

អ្នកបោះឆ្នោតត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងមិនត្រូវស្ថិតក្រោមការហាមប្រាមនិងស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញដែលត្រូវមានកាតព្វកិច្ចដើម្បីបោះឆ្នោតនៅការបោះឆ្នោតនីមួយៗ។ការខកខានសមស្របណាមួយដែលមិនបានទៅបោះឆ្នោតនៅក្នុងមណ្ឌលបោះ
ឆ្នោតណាមួយត្រូវជូនដំណឹងទៅគណៈកម្មការរៀបចំការបោះឆ្នោតទៅមណ្ឌលខ្លួនមិនតិចជាងប្រាំពីរថ្ងៃមុនថ្ងៃបោះឆ្នោត។ប្រសិនបើមូលហេតុនៃការជូនដំណឹងគឺមិនសមហេតុផល គាត់ នឹង ផ្តល់ដំណឹងត្រឡប់ ដោយគ្មានការពន្យាពេល ដោយ រយៈពេល មិនតិចជាងបីថ្ងៃមុន ថ្ងៃ បោះឆ្នោត។គណៈកម្មការរៀបចំការបោះឆ្នោតត្រូវប្រកាសឡើងបញ្ជីនៃជនដាក់ស្នើការជូនដំណឹងបែបនេះនឹងកន្លែងហើយវិធីសាស្ត្រនៃការជូនដំណឹងនៅ ការិយាល័យខេត្ត ស្រុក ក្រុងការិយាល័យរដ្ឋបាលនិងឃុំ។

### ខ. បេក្ខជនសភាតំណាង

អ្នកដែលមានសិទ្ធិក្នុងការក្លាយជាបេក្ខជននៅក្នុងការបោះឆ្នោតរបស់សមាជិកនៃសភាតំណាងត្រូវតែងតាំង នៅក្នុងបញ្ជី គណបក្សនៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតសភាតំណាងណាមួយហើយត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមិនត្រូវ

ស្ថិតក្រោមការហាមប្រាមសម្រាប់បេក្ខជនក្នុងការបោះឆ្នោតរបស់សមាជិកនៃសភាតំណាង ស្របតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ។គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបានបោះពុម្ពផ្សាយ នៅក្នុងមណ្ឌលរដ្ឋបាលនូវសេចក្តីលម្អិតដែលទាក់ទងទៅនឹងភស្តុតាងនៃនីតិវិធីទទួលបាន បេក្ខភាពបន្ទាប់ពីនាយកនៃមណ្ឌលបោះឆ្នោតបានទទួលនីតិវិធីនោះគាត់ត្រូវកត់ត្រាការ ទទួលយកផ្សាយជាភស្តុតាងនិងចេញវិក័យប័ត្រមួយបញ្ជាក់នៅថ្ងៃដូចគ្នានេះ។នាយកការ បោះឆ្នោត នោះនឹងត្រូវបាន ពិនិត្យ ភស្តុតាងនៃ លក្ខណៈសម្បត្តិ និងធ្វើឱ្យការស៊ើបអង្កេត ជា សិទ្ធិទទួលបាន ការ បេក្ខជន ដែលនឹងត្រូវបាន បញ្ចប់ក្នុងរយៈពេល ប្រាំពីរ ថ្ងៃចាប់ពីថ្ងៃ បិទសម្រាប់កម្មវិធីនេះ។ប្រសិនបើអ្នកដាក់ពាក្យស្នើសុំគឺមានសិទ្ធិទទួលសេចក្តីជូនដំណឹង អំពការទទួលយកបេក្ខភាពរបស់គាត់ត្រូវបិទនៅ ការិយាល័យខេត្ត ស្រុក ឃុំជាដើម។ ត្រូវមានឈ្មោះបេក្ខជន រូបថតគណបក្សនយោបាយ នីមួយៗត្រូវមានបេក្ខជនបម្រុងទុក ដែលត្រូវប្រើក្នុងការបោះឆ្នោត នៅក្នុង សំណុំបែបបទ ដូចមានចែង ដោយ គណៈកម្មាធិ ការបោះឆ្នោត។ក្នុងករណីដែលបេក្ខជនត្រូវបានរកឃើញពុំសក្តិសមដើម្បីប្រកួតប្រជែង ក្នុងការបោះឆ្នោតប្រធាន មណ្ឌលបោះឆ្នោតត្រូវពិនិត្យភស្តុតាងនៃលក្ខណៈសម្បត្តិនៃ បេក្ខជន ដូច ដោយគ្មានការពន្យាពេល មុនពេល ដាក់ស្នើ សំណើ មួយទៅ តុលាការកំពូល ដើម្បីច្រានចោលបេក្ខជននោះ។ដើម្បីធានាបាននូវភាពយុត្តិធម៌ ក្នុងការដំណើរការ កិច្ច ដំណើរការនីតិវិធីនៅក្រោមដោយគ្មានពន្យាពេលប្រធាននៃតុលាការកំពូលដោយមានការ យល់ព្រមពីក្រុមប្រឹក្សាភិបាលនៃសហចៅក្រមកំពូលនឹងចេញដីកាមានព័ត៌មានលម្អិត ទាក់ទងទៅនឹងបញ្ហាបែបនេះនៅក្នុងមណ្ឌលរដ្ឋបាល។កិច្ចដំណើរការនីតិវិធីបែបនេះ របស់ តុលាការកំពូលត្រូវបានបញ្ចប់ដោយថ្ងៃមុនថ្ងៃបោះឆ្នោតនោះ។តុលាការកំពូលអាច នឹងផ្តល់តុលាការភស្តុតាងដំបូងនៅក្នុងមណ្ឌលបោះឆ្នោតមួយដើម្បីទទួលបានការ ចលនា ពិនិត្យភស្តុតាងឬអនុម័តកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធផ្សេងទៀតដូចជាចាត់ទុក ការចាំ បាច់។បញ្ជីគណបក្សសម្រាប់បេក្ខភាពនៅលើមូលដ្ឋានគណបក្សអនុលោមតាមគោល ការណ៍ដូចខាងក្រោមៈ

(១)បញ្ជីគណបក្ត្រូវមានឈ្មោបេក្ខជនស្មើភាពគ្នាពីតំបន់ផ្សេងគ្នា

(២)គណបក្សនយោបាយដែលបានតែងតាំងបុគ្គលណាមួយនឹងបានទទួលភស្តុ តាងនៃ ការយល់ព្រម ពីមនុស្សម្នាក់ ដែលនឹងក្លាយជាសមាជិករបស់គណបក្សនយោបាយ ថាមានតែថា

(៣)បញ្ជីគណបក្សនេះនឹងត្រូវបានរៀបចំនៅក្នុងសំណុំបែបបទដូចមានចែង ដោយ គណៈកម្មាធិការបោះឆ្នោតដោយលំដាប់លេខដែលមិនត្រូវលើសពីមួយរយនាក់។នៅ

ក្នុងការបោះឆ្នោតជាទូទៅមួយគណបក្សនយោបាយដាក់បញ្ជីគណបក្សមួយដែលនឹងត្រូវបាន បម្រុងទុកសម្រាប់ លេខ អត្តសញ្ញាណ បេក្ខជន ទៅបោះឆ្នោត នៅឯការបោះឆ្នោតដោយលំដាប់រៀងនៃការដាក់ស្នើបញ្ជីគណបក្ស។នៅក្នុងករណីនៃការបោះឆ្នោតដើម្បីបំពេញទំនេររបស់សមាជិកនៃសភាតំណាងជាប់ឆ្នោតមកពីការបោះឆ្នោតលើមូលដ្ឋាន ណាមួយ ដែល បេក្ខជន ត្រូវ បានផ្តល់ លេខ អត្តសញ្ញាណបេក្ខជន តាមលំដាប់ រៀង នៃកម្មវិធីនេះ។ប្រសិនបើបេក្ខជនបានដាក់ស្នើកម្មវិធីនៅពេលតែមួយនិងលេខអត្តសញ្ញាណបេក្ខជនមិនអាចត្រូវបានយល់ព្រមដោយលេខអត្តសញ្ញាណបេក្ខជនបេក្ខជនបែបនេះ នឹងត្រូវបានដកចេញដោយការចាប់ឆ្នោត។

### គ. ការចំណាយលើយុទ្ធនាការបោះឆ្នោត

កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើប្រាស់នៃព្រះរាជក្រឹត្យស្តីពីការបោះឆ្នោតរបស់សមាជិកនៃសភាតំណាងនៅក្នុងមណ្ឌលបោះឆ្នោតថ្ងៃបោះឆ្នោតណាមួយដែលជាការចំណាយបោះឆ្នោតនិងមធ្យោបាយនៃយុទ្ធនាការបោះឆ្នោតសមាជិកនៃសភាតំណាងគណៈកម្មការរៀបចំការបោះឆ្នោតត្រូវចេញការជូនដំណឹងកំណត់ការចំណាយការបោះឆ្នោតដូចខាងក្រោមនេះ៖

(១)ចំនួនទឹកប្រាក់នៃការចំណាយរបស់បេក្ខជននៅក្នុងការបោះឆ្នោត

(២)ចំនួនទឹកប្រាក់នៃការចំណាយនៃគណបក្សនយោបាយក្នុងករណីបេក្ខជនក្នុងបញ្ជី គណបក្សនយោបាយណាមួយបានចំណាយនៅក្នុងការបោះឆ្នោតសម្រាប់ការចំនួនទឹកប្រាក់នៃការចំណាយ ណាមួយ ចំនួន ដូច នោះនឹងត្រូវបាន រួមបញ្ចូលនៅក្នុង ការចំណាយនៃគណបក្សនយោបាយនោះ។ក្នុងការកំណត់បរិមាណនៃការចំណាយនៅក្នុងការបោះឆ្នោតគណៈកម្មាការរៀបចំការបោះឆ្នោតត្រូវពិគ្រោះជាមួយមេដឹកនាំនៃគណបក្សនយោបាយបេក្ខជនឬគណបក្សនយោបាយមិនត្រូវបង់នៅក្នុងការបោះឆ្នោតលើសពីចំនួនទឹកប្រាក់នៃការចំណាយបានកំណត់ការចំណាយបែបនេះនឹងមានរួមទាំងប្រាក់ទាំងអស់ឬទ្រព្យសម្បត្តិ ផ្សេងទៀតបង់ ឬការ សន្យាថានឹង បង់ ដោយបុគ្គល ណាមួយក្នុងនាមជាបេក្ខជន ឬគណបក្សនយោបាយឬ បានផ្តល់ នឹងត្រូវ បានប្រើសម្រាប់ គោលបំណង នៃយុទ្ធនាការ បោះឆ្នោតដោយគ្មានសំណងដោយមានការយល់ព្រមពីបេក្ខជនឬគណបក្សនយោបាយ។នៅក្នុងករណី នៃការផ្តល់ទ្រព្យសម្បត្តិតម្លៃរបស់វានឹងត្រូវបានគណនាដោយយោងទៅតាម អត្រានៃការ ជួល ធម្មតា ឬ សំណង នៅក្នុង តំបន់ នោះ។បេក្ខជន ឬ គណបក្សនយោបាយ ដែលជា ករណី អាច នឹង តែងតាំង មនុស្សណាមួយសមរម្យដើម្បីឱ្យមានការទទួលខុសត្រូវ សម្រាប់ផ្នែកហិរញ្ញិក មានការរៀបចំនិងការបញ្ជាក់គណនី ចំណូលនិង

ការចំណាយ របស់ បេក្ខជនឬគណបក្សនយោបាយនៅក្នុងការបោះឆ្នោតនេះ។ការរៀបចំនៃគណនីចំណូល

និងចំណាយនៃការរតនសម្បត្តិត្រូវស្របតាមច្បាប់និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការបោះឆ្នោតដោយបោះពុម្ពផ្សាយនៅក្នុងរដ្ឋាភិបាលរាជកិច្ច។នៅក្នុងរយៈពេលកៅសិបថ្ងៃដូចជាមកពីកាលបរិច្ឆេទនៃការប្រកាសពីលទ្ធផលនៃការបោះឆ្នោតមួយបេក្ខជននីមួយឬបេក្ខជនតែងតាំងគណបក្សនយោបាយ នៅលើមូលដ្ឋាន គណបក្សបញ្ជី នេះ ត្រូវ ដាក់ ក្នុង គណនី ប្រាក់ចំណូល និងការចំណាយ រៀបចំដោយរតនសម្បត្តិ និងបានបញ្ជាក់ដោយ បេក្ខជន ឬ មេដឹកនាំ នៃគណបក្សនយោបាយ ដែលជា ករណី អាច ទៅ គណៈកម្មាធិ ការ បោះឆ្នោត។ចំណូលនិងការចំណាយយ៉ាងហោចណាស់ក៏គណនីត្រូវមានការចំណាយទាំងអស់បានបង់និងការចំណាយដែលកើតឡើងនោះរួមទាំងភស្តុតាងដែលពាក់ព័ន្ធមានភាពត្រឹមត្រូវនិងពេញលេញ។បន្ទាប់ពីការពិនិត្យពិសេសគឺការចំណាយគណៈកម្មាការរៀបចំការបោះឆ្នោតត្រូវប្រកាសលទ្ធផលនៃការប្រឡងនៃការចំណាយបែបនេះស្របតាមច្បាប់និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការបោះឆ្នោត។ក្នុងករណីដែលមានការជំទាស់ការបោះឆ្នោតដែលបេក្ខជនណាមួយឬគណបក្សនយោបាយណាមួយបានចំណាយនៅក្នុងការ បោះឆ្នោត លើសពី ចំនួនទឹកប្រាក់នៃការ ចំណាយ កំណត់ដោយគណៈកម្មការ រៀបចំការបោះឆ្នោត មួយពិសេសគដូចជា ការចំណាយនិង ភស្តុតាងដែលពាក់ព័ន្ធ នឹង ត្រូវបានរក្សាទុករហូតដល់គណៈកម្មការរៀបចំការបោះឆ្នោតបានបញ្ចប់នីតិវិធី។ក្នុងករណីដែលមានបង្ហាញភស្តុតាងនៃការបញ្ចុះបញ្ចូលការរំលោភលើបទប្បញ្ញត្តិស្ដីពីការឃោសនាណាមួយដែលគណៈកម្មាការរៀបចំការបោះឆ្នោត មានអំណាច បញ្ជា ជាផ្លូវការ របស់រដ្ឋ ដូចជាទៅបញ្ឈប់ឬផ្អាកទង្វើផ្សាយ។ចំពោះគោលបំណងនេះគណៈកម្មាការរៀបចំការបោះឆ្នោតត្រូវជូនដំណឹងដល់គូប្រៀបនៃការជាផ្លូវការនោះក្នុងការបញ្ជាជាផ្លូវការថាដូចជាត្រូវមានកាតព្វកិច្ចសម្រាកជាដើម។

### ផ្នែកទី៣. អំពីពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោត

#### ក. នីតិវិធីក្នុងការិយាល័យបោះឆ្នោត

ប្រអប់សន្លឹកឆ្នោតនឹងត្រូវបានគេមើលឃើញនៅខាងក្នុងនៃប្រអប់ហើយនឹងត្រូវបានផ្សាភ្ជាប់នឹងបង្ការការបើកខុសច្បាប់ណាមួយនៃប្រអប់សន្លឹកឆ្នោតឬការបញ្ចូលសន្លឹកឆ្នោតនៅក្នុងប្រអប់សន្លឹកឆ្នោតបន្ទាប់ពីបោះឆ្នោតត្រូវបានបញ្ចប់និងត្រូវមានការពិពណ៌នាជាក់លាក់ដើម្បីការពារការផ្លាស់ប្តូរនៃប្រអប់សន្លឹកឆ្នោត។សមាជិកនៃសភាតំណាងនៅមណ្ឌលមួយត្រូវបញ្ជាក់ទាំងអស់លេខអត្តសញ្ញាណបេក្ខជននៃបេក្ខជនទាំងអស់នៅក្នុង

មណ្ឌលបោះឆ្នោត។ ក្រដាសសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតនៃសមាជិកនៃសភាតំ

ណាងលើបញ្ជីគណបក្សត្រូវបញ្ជាក់ចំនួនដែលបានបម្រុងទុក។ នៅថ្ងៃបោះឆ្នោត បោះឆ្នោតនឹងចាប់ផ្តើមពីម៉ោង៨:00ព្រឹកដល់ម៉ោង៣:00រសៀល។មុនពេលការសម្តែងនៃការបោះឆ្នោតគឺត្រូវបានចាប់ផ្តើមគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតមួយនឹងរាប់ចំនួនសរុបនៃក្រដាសសន្លឹកឆ្នោតនៃស្ថានីយ៍បោះឆ្នោតបែបនិងត្រូវប្រកាសឡើងសេចក្តីជូនដំណឹងអំពីចំនួនសរុប នៃសន្លឹកឆ្នោតមួយនៅឯកន្លែងក្នុងគំនិតនេះ។ នៅពេលដែលបោះឆ្នោតត្រូវបានចាប់ផ្តើមគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតមួយជាសាធារណៈនឹងបើកប្រអប់សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតមានវត្តមាននៅកន្លែងបោះឆ្នោតនេះឃើញថាប្រអប់សន្លឹកឆ្នោតគឺទទេហើយបន្ទាប់មក ត្រូវបិទប្រអប់សន្លឹកឆ្នោត ស្របតាមនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការបោះឆ្នោតនិងត្រូវ កត់ត្រា ដំណើរការ បែបនេះ ដោយ មាន មិនតិច ជាងពីរអ្នកបោះឆ្នោតមានវត្តមាន នៅកន្លែងបោះឆ្នោតនៅពេលនោះដើម្បីដាក់ផ្ទាប់ហត្ថ លេខារបស់ពួកគេមានជាធរមានលើកលែងតែមានវត្តមានបោះឆ្នោតទេនៅពេលនោះ។ ក្នុងអំឡុងពេលម៉ោងបោះឆ្នោត,ការបោះឆ្នោតដែលមានបំណងទៅបោះឆ្នោតមួយនឹងណត់អត្តសញ្ញាណខ្លួនឯងឬខ្លួននាងទៅគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតមួយដោយផលិតអត្តសញ្ញាណប័ណ្ណនេះអត្តសញ្ញាណប័ណ្ណដែលផុតកំណត់ឬកាតផ្លូវការផ្សេងទៀតឬភស្តុតាងដែលមានរូបថតដែលអាចកំណត់អត្តសញ្ញាណខ្លួនឯងតាមមួយជាមួយនឹងនីតិវិធីដែលបានកំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតនៅក្នុរាជកិច្ចនៅពេលដលគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតមួយបានពិនិត្យឈ្មោះនៅក្នុងការបោះឆ្នោតនិងអាសយដ្ឋានរបស់បុគ្គលនោះ។ប្រសិនបើ កត់សម្គាល់ថាមានជនមិនប្រក្រតីមកធ្វើការបោះឆ្នោតគេត្រូវឲ្យជននោះចុះហត្ថលេខា ឬស្នាមម្រាមដៃ។បន្ទាប់មកគណៈកម្មាធិការស្ថានីយ៍បោះឆ្នោត មួយនឹងផ្តល់ក្រដាសសន្លឹកឆ្នោតទៅមនុស្សបែបនេះសម្រាប់បោះឆ្នោតក្នុងករណីដែលមាន ការសង្ស័យ ឬគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតមួយដែល សង្ស័យថាបច្ចុប្បន្ន ការបោះឆ្នោតគឺមិនមែនជាមនុស្សម្នាក់ដែលមានឈ្មោះនៅក្នុងការបោះឆ្នោតនោះវិលជុំ

មួយគណៈកម្មាធិការនឹងមានអំណាចក្នុងការស៊ើបអង្កេតនិងធ្វើឱ្យការសម្រេចចិត្ត ថាតើមនុស្សម្នាក់ត្រូវបានគេជំទាស់ឬសង្ស័យថានេះគឺជាការមនុស្សម្នាក់ដែលមានឈ្មោះនៅក្នុងការបោះឆ្នោតវិលជុំគណៈកម្មាធិការការសម្រេចចិត្តបែបនេះត្រូវកត់ត្រា និងចុះហត្ថលេខាឈ្មោះរបស់ពួកគេ។ក្នុងករណីដែលជាកន្លែងដែលករណីប្រធានសក្តិឡើយនៅក្នុងនៅ

ថ្ងៃបោះឆ្នោតគណៈកម្មាធិការស្ថានីយ៍បោះឆ្នោតត្រូវប្រកាសលុបចោលការបោះឆ្នោតនៅក្នុងស្ថានីយ៍និងរាយការណ៍ទៅគណកម្មាធិការបោះឆ្នោតជាបន្ទាន់នោះ។គណៈកម្មការ រៀបចំការបោះឆ្នោតត្រូវជួសជុលថ្ងៃបោះឆ្នោតថ្មីមួយនៃស្ថានីយ៍បោះឆ្នោតបែបនេះក្នុងរយៈពេលសាមសិបថ្ងៃដូចជាចាប់ពីថ្ងៃដែលលុបចោលការបោះឆ្នោត និត្រូវប្រកាសការអនុវត្ត ថ្ងៃបោះឆ្នោតនេះយ៉ាងហោចណាស់ប្រាំពីរថ្ងៃមុនថ្ងៃបោះឆ្នោត ។

## ខ.ការរាប់សន្លឹកឆ្នោតនិងប្រកាសលទ្ធផល

ការរាប់សន្លឹកឆ្នោតនៃការបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតណាមួយនឹងចាប់ផ្តើមនៅពេលដែលប្រអប់សន្លឹកឆ្នោតទាំងអស់ពីស្ថានីយ៍បោះឆ្នោតទាំងអស់នៅក្នុងមណ្ឌលបោះឆ្នោតមកដល់នៅកន្លែងដែលបានកំណត់នៃការរាប់សន្លឹកឆ្នោត។ នៅក្នុងករណីនៃភាពចាំបាច់ក្នុងភូមិសាស្រ្តណាលណាមួយដែលគណៈកម្មការរៀបចំការបោះឆ្នោត ត្រូវផ្តល់ជាកន្លែងបន្ថែមទៀតនៃការរាប់សន្លឹកឆ្នោតដើម្បីបញ្ចប់ការរាប់សន្លឹកឆ្នោតដោយគ្មានការពន្យាពេល។ក្នុងករណីដែលជាកន្លែងដែលប្រអប់សន្លឹកឆ្នោតពីមណាណាមួយ មកដល់ នៅកន្លែងដែលបានកំណត់ នៃការ រាប់សន្លឹកឆ្នោតយឺតចាង១២ម៉ោងបន្ទាប់ពីពេលវេលា នៃការបិទបោះឆ្នោត ដោយគ្មានហេតុផលភស្តុតាង និងស្របច្បាប់នេះ គណកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ឈប់ការរាប់ ឬហាមបើកប្រអប់សន្លឹកឆ្នោតពីស្ថានីយ៍និងបញ្ជារឱ្យមានការបោះឆ្នោតថ្មីមួយសម្រាប់ស្ថានីយ៍នោះ។ចំពោះគោលបំណងថាការ រាប់សន្លឹកឆ្នោតត្រូវបានអនុវត្តដោយបើកចំហានិងយុត្តិធម៌ស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញដែលជាគណៈកម្មាការរៀបចំការបោះឆ្នោតត្រូវចេញបញ្ជាក្នុងលិខិត្តរដ្ឋបាលផ្អែកលើនីតិវិធីបោះឆ្នោតដែលត្រូវអញ្ជាក់ព័ត៌មានដូចខាងក្រោម៖

(១) នីតិវិធី នៃការទទួល ការពិនិត្យនិងបើកប្រអប់សន្លឹកឆ្នោតនិងការប្រគល់ឯកសារនិង ភស្តុតាងដែលទាក់ទងទៅនឹងការបោះឆ្នោតមួយសម្រាប់ភាពត្រឹមត្រូវនៃចំនួនសន្លឹកឆ្នោតនេះជាការទទួលបានប្រអប់សន្លឹកឆ្នោតដែលនឹងត្រូវបានទាក់ទងទៅលេខ នេះសន្លឹកឆ្នោតបានបញ្ជូន ទៅកាន់ ស្ថានីយ៍បោះឆ្នោត គ្នា មុនពេលការសម្តែង នៃសម្លេងឆ្នោត និងវិធាននៃការពិចារណាឱ្យមានការបោះឆ្នោតការរាប់ជាថ្មីនៅកន្លែងដែលសន្លឹកឆ្នោតមិនប្រក្រតី

(២)នីតិវិធីដើម្បីរក្សាប្រអប់សន្លឹកឆ្នោតឬក្រដាសសន្លឹកឆ្នោតសម្រាប់ការរាប់សន្លឹកឆ្នោតនេះត្រូវបានអនិវត្ត

(៣) នីតិវិធី ក្នុងការផ្តល់នូវ កន្លែង ដែលបានកំណត់ នៃការរាប់សន្លឹក ឆ្នោត និងដើម្បី អានការសម្តែងនៃការបោះឆ្នោតនៅក្នុងសន្លឹកឆ្នោតដែលត្រូវធ្វើជាសាធារណៈដើម្បីជួយសម្រួលដល់មនុស្សម្នាក់ដែលបង្ហាញនៅក្នុងកន្លែងនៃការរាប់សន្លឹកឆ្នោតដើម្បីមើល

ដំណើរការសវនាការនេះ

(៤)នីតិវិធីដើម្បីពិនិត្យមើលការសម្តែងនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយនៅពេលដែលមានការជំទាស់ថាការសម្តែងនៃសន្លឹកឆ្នោតដូចត្រូវបាន៦ដោយសច្បាប់មួយ

(៥)នីតិវិធីស្តីពីការបោះឆ្នោតការរាប់និងផ្តល់លទ្ធផលនៃការបោះឆ្នោតសម្រាប់ការបោះឆ្នោតនិងត្រូវជូនដំណឹងដល់លទ្ធផលនេះនៃការបោះឆ្នោតដែលត្រូវបានរាបគណៈកម្មការរៀបចំការបោះឆ្នោតដើម្បីគណនាលទ្ធផលសរុបផ្សាយនៅទូទាំងប្រទេស។បន្ទាប់ពីទទួលបានលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅក្នុងការបោះឆ្នោតមួយនៅលើមូលដ្ឋាននៃការគណនានៃចំនួនសមាជិកជាប់ឆ្នោតរបស់សភាលើមូលដ្ឋានគណបក្សបញ្ជីនៃគណបក្សនយោបាយគណៈកម្មការរៀបចំការបោះឆ្នោតត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតមួយនៅលើមូលដ្ឋានបញ្ជីគណបក្ស។នៅពេលដែលគណៈកម្មាការរៀបចំការបោះឆ្នោតបានប្រកាស លទ្ធផលនៃ ការបោះឆ្នោត មួយ នេះវានឹង ជូនដំណឹងដល់ លទ្ធផលនៃ ការបោះឆ្នោត ដើម្បីសភាជាតិសំរាប់ការទទួលស្គាល់និងការបោះពុម្ពផ្សាយវានៅក្នុងរាជកិច្ច។គណៈកម្មការ រៀបចំការបោះឆ្នោត ក៏ ត្រូវ ដាក់ស្នើ បញ្ជី គណបក្ស នៃ រាល់ គណបក្សនយោបាយ ទៅប្រធានសភាតំណាង។

**គ.ការបន្លំក្នុងពេលបោះឆ្នោតនិងការដោះស្រាយបណ្តឹង**

នៅក្នុងករណីនេះគណៈកម្មាការរៀបចំការបោះឆ្នោតបានស៊ើបអង្កេតមុនពេលការប្រកាសពីលទ្ធផលនៃការបោះឆ្នោតមួយនិងបានរកឃើញ ភស្តុតាង ណាមួយដែល បេក្ខជនណាមួយដែលបានរំលោភច្បាប់និងបានសម្របសម្រួលមនុស្សផ្សេងទៀតដើម្បីប្រព្រឹត្តការរំលោភបែបនេះឬមិនបានបញ្ឈប់ការរំលោភនិងការរំលោភបែបនេះបានបណ្តាលឱ្យការប្រព្រឹត្តនៃការបោះឆ្នោតដើម្បីឱ្យមានខុសច្បាប់និងអយុត្តិធម៌មួយនេះ។ គណៈកម្មការ រៀបចំការបោះឆ្នោត ត្រូវមាន អំណាចដើម្បីដកហូត សិទ្ធិ បោះឆ្នោត របស់ បេក្ខជនបែបនេះសម្រាប់មួយឆ្នាំការទទួលឥទ្ធិពលពីកាលបរិច្ឆេទនៃការជូនដំណឹងនៃគណៈកម្មការរៀបចំការបោះឆ្នោតនោះ។សេចក្តីសម្រេចរបស់គណៈកម្មាធិការបោះឆ្នោតក្នុងកាដកហូតសិទ្ធិ បោះឆ្នោត របស់ បេក្ខជននឹងត្រូវបាន ដោយផ្អែកលើមូលដ្ឋានការមូលមតិគ្នា មួយ។បន្ទាប់ពីគណៈកម្មការរៀបចំការបោះឆ្នោតបានដកហូតសិទ្ធិបោះឆ្នោតរបស់បេក្ខជនណាមួយបេក្ខជនដូចក៏នឹងត្រូវទទួលការកាត់ទោសក្រោមក្រមនីធី ព្រហ្មទណ្ឌ។ក្នុងករណីដើម្បី ដកហូត សិទ្ធិ បោះឆ្នោត របស់ បេក្ខជន មួយ ត្រូវបាន ចេញបន្ទាប់ពី ការប្រកាសពីលទ្ធផលនៃការបោះឆ្នោតនិងបេក្ខជនដូចជាទទួលបានមានចំនួនច្រើនបំផុតនៃការបោះ

ឆ្នោតនៅលើមូលដ្ឋានណាមួយគណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ជាឱ្យការបោះឆ្នោតថ្មីយនៅក្នុងមណ្ឌលបោះឆ្នោតបែបនោះ។ដើម្បីធានាថា ការស៊ើបអង្កេតមួយ ត្រូវបានធ្វើឡើង ដោយស្មើភាពដោយគ្មានការពន្យាពេលនេះគណៈកម្មាធិការបោះឆ្នោតត្រូវតែងតាំងព្រះ

រាជអាជ្ញាសាធារណៈរដ្ឋមន្ត្រីផ្សេងទៀតដែលជាអតីតព្រះរាជអាជ្ញាសាធារណៈអតីតចៅក្រម ឬ អតីត មន្ត្រី រដ្ឋ ការបង្កើត គណៈកម្មាធិ និងការជួយនៅក្នុងកិច្ចដំណើរការនីតិវិធី នៃការស៊ើបអង្កេតមួយ។ព្រះរាជអាជ្ញាសាធារណៈនិងមន្ត្រីរដ្ឋដទៃទៀតនឹងជួយដល់គណៈកម្មាធិការបោះឆ្នោតតាមលំដាប់តែងតាំងដោយគ្មានការយល់ព្រមជាមុនពីអង្គការរបស់ខ្លួន។វិធាននិងនីតិវិធីសម្រាប់កិច្ចដំណើរការនីតិវិធីបែបនេះនឹងត្រូវបាន កំណត់ដោយ គណៈកម្មការ រៀបចំការបោះឆ្នោត ។ការតែងតាំងសហព្រះរាជអាជ្ញា សាធារណៈឬ មន្ត្រី រដ្ឋផ្សេងទៀតនឹងត្រូវបាន ប្រកាសដោយ ព្រះរាជក្រឹត្យស្តីពីការបោះឆ្នោត។ សំណង នៃការ ព្រះរាជអាជ្ញា មន្ត្រីសាធារណៈឬ មន្ត្រី រដ្ឋ ផ្សេងទៀត នឹងត្រូវបាន កំណត់ដោយ គណៈកម្មការ រៀបចំការបោះឆ្នោត ។បន្ទាប់ពី ការបោះឆ្នោត ការរាប់ ករ បានបញ្ចប់ ក្នុង -ករណីមានភស្តុតាងពីការក្លែងបន្លំការបោះឆ្នោតបញ្ចុះបញ្ចូលក្នុងការបោះឆ្នោតនៅលើមូលដ្ឋានណាមួយគកម្មការរៀបចំការបោះឆ្នោតត្រូវមានអំណាចដើម្បីលុបចោលការប្រកាសពីលទ្ធផលនៃការបោះឆ្នោតនិងការបញ្ជារឱ្យមានការបោះឆ្នោតថ្មីមួយ។ ក្នុងការបន្តការស៊ើបអង្កេតលើការក្លែងបន្លំការបោះឆ្នោតនិងនៅក្នុងការការពារការក្លែងបន្លំការបោះឆ្នោតដែលជា គណៈកម្មការរៀបចំការបោះឆ្នោត ឬ ស្នងការ តែងតាំង មួយ ត្រូវមាន អំណាចដូចខាងក្រោមៈ

(១) ការបញ្ចូល និងការ ស្វែងរក ការរឹបអូស ទ្រព្យសម្បត្តិ ឯកសារ ឬ ភស្តុតាងនៅក្នុងផ្ទះបរិវេណឬរថយន្តដោយគ្មានដីកាតុលាការនៅពេលដែលមានភស្តុតាងណាមួយបញ្ចុះបញ្ចូលនៃការរំលោភច្បាប់កំណត់គ្រាលម្អិតលើនីតិវិធីបែបនេះត្រូវបានធ្វើបានផ្តល់។ អំណាចក្រោមកថាខណ្ឌមួយនឹងត្រូវបានប្រកាសឱ្យប្រើនៅក្នុងបែបផែនពីនៃព្រះរាជក្រឹត្យស្តីពីការបោះឆ្នោតរបស់សមាជិកនៃសភាតំណាងដល់ការប្រកាសលទ្ធផល នៃការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតអាចនឹងតែងតាំងមន្ត្រីរដ្ឋផ្សេងទៀតដើម្បីជួយដល់កិច្ចដំណើរការនីតិវិធីដូចជាការចាត់ទុកការចាំបាច់។នៅក្នុងករណីនេះគណៈកម្មាធិការបោះឆ្នោតសមាជិកនៃគណៈកម្មាធិការបោះឆ្នោតឬមន្ត្រីរដ្ឋផ្សេងទៀតដើម្បីអនុម័តអំណាចដែលស្ថិតនៅក្រោមកថាខណ្ឌមួយ,ដំណើរការនីតិវិធីបែបនេះនឹងត្រូវបានអនុម័តដោយ

មានដីកាតុលាការ។

(២)ស្នើគណៈកម្មាធិការប្រឆាំងការលាងលុយផ្តល់នូវរបាយការណ៍របស់បុគ្គលដែលបានចូលរួមនៅក្នុងការបោះឆ្នោតមួយដែលមានប្រតិបត្តិការហិរញ្ញវត្ថុ។កិច្ចដំណើរការនីតិវិធីបែបនេះក៏នឹងត្រូវបានអនុវត្តទៅធនាគារនៃប្រទេសថៃដែលជាធនាគរពាណិជ្ជដែបានចុះបញ្ជីឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។

## សេចក្តីសន្និដ្ឋា

ប្រព័ន្ធច្បាប់បើឆ្នោតគឺមានសារៈសំខាន់ណាស់សម្រាប់ប្រទេដែលប្រកាន់នូវរបបប្រជាធិបតេយ្យពោលគឺការបើឆ្នោតនេះហើដែលជាឪកាសដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋនៅក្នុងរដ្ឋនេះប្រើប្រាស់នូវសិទ្ធិសេរីភាពរបស់គាត់ក្នុងការជ្រើសរើសអ្នកដឹកនាំរដ្ឋ។ យ៉ាងណាក្តីការបោះឆ្នោតអាចប្រព្រឹត្តទៅបានដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌គឺពិតជាអាស្រ័យទៅលើប្រព័ន្ធច្បាប់នៃការបោះឆ្នោនោះផងដែរដូក្នុងករណីមានគំរូភាពនៃប្រព័ន្ធច្បាប់បោះឆ្នោតនៃប្រទេសថៃ និងកម្ពុជាដែលបានរៀបរាប់ខាលើស្រាប់ជាគំរូ។ គេសង្កេតឃើញថាប្រព័ន្ធច្បាប់នៃប្រទេសទាំពីហាក់មិនសូវជាខុសគ្នាប៉ុន្មាទេនៅក្នុងលក្ខណៈតាមបែបជាទំរង់តែមានភាពខុសគ្នាខ្លះក្នុងលក្ខណៈបច្ចេកទេសគិតចាប់ពីនិតិវិធីចុះឈ្មោះបោះឆ្នោត រហូតដល់ការប្រកាសលទ្ធផលនៃការបោះឆ្នោតទាំមូលជាផ្លូវការ។ តែទោះជាយ៉ាងណាគេសំគាល់ឃើញថាប្រព័ន្ធនៃច្បាប់បោះឆ្នោតរវាងប្រទេសទាំងពីមានភាពខុសគ្នាស្រលះត្រង់ក្នុងករណីសមត្ថកិច្ចដោះស្រាយវិវាទបោះឆ្នោត គឺករណីប្រទេសថៃត្រូបាបគេប្រគល់សមត្ថកិច្ចនេះទាំស្រុងទៅឲ្យតុលាការជាអ្នកដោះស្រាយ និងបិទផ្លូវតវ៉ា ចំណែកប្រទេសកម្ពុជាវិញត្រូវបានគេមើលឃើញថាក្រុមប្រឹក្សាធម្មនុញ្ញជាសមត្ថកិច្ចបិទផ្លូវចុងក្រោយ។

## អនុសាសន៍

ផ្អែកលើការសិក្សាពីករណីប្រព័ន្ធច្បាប់បោះឆ្នោតប្រទេសកម្ពុជា និងផ្អែកលើការសិក្សាពីករណីប្រព័ន្ធច្បាប់បោះឆ្នោតរបស់ប្រទេសថៃ និងឆ្លងតាមការសិក្សាពីស្ថានភាពជាក់ស្តែងក្នុងការអនុវត្តកន្លងមកអាចទាញបាននូវគំនិតជាពិចារណាចំនួន៤ ចំណុចសម្រាប់ជាធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធច្បាប់បោះឆ្នោតនៅកម្ពុជាដូចខាង ក្រោម៖

១.គណៈកម្មាធិការជាតិរៀបចំការបោះត្រូវពិនិត្យសើរើឡើងវិញនូវរាល់ពញ្ជីឈ្មោះស្ទួនដែលនៅសេសសល់កន្លងមកដែលជាឧបសគ្គក្នុងការគ្រប់គ្រងបញ្ជីឈ្មោះបោះឆ្នោត។

២.ត្រូវរក្សាទុកនូវសមាសភាពនៃគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបន្តធ្វើកិច្ចការខាងលើដោសហការជាមួយភាគីពាក់ព័ន្ធរហូតកិច្ចការនេះត្រូវបានបញ្ចប់។

៣.ត្រូវកំណត់អំពីដែនកំណត់ ប្រភពនៃថវិការសម្រប់ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឲ្យមានសុក្រឹត្យភាព និងតម្លាភាព។

៤.សម្តកិច្ចដោះស្រាយលើដណ្តឹងពីការបោះឆ្នោតគឺជាសមត្ថកិច្ចរបស់តុលាការកំ ពូលមិនមែនក្រុមប្រឹក្សាធម្មនុញ្ញ។